## ការព្រមព្រៀង ជាឯកច្ឆន្ទខាងនយោបាយ បន្ទាន់មួយ ដើម្បីការពារសិទ្ធិមនុស្ស លោក បាន បានថ្លែងក្នុងឱកាសបើកសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប

២ មីនា ឆ្នាំ២០១៥ – លោក បាន គី-មូន អគ្គលេខាធិការអង្គការសហប្រជាជាតិ បានមានប្រសាសន៍ទៅកាន់គណៈប្រតិភូទាំងឡាយ ដែលចូលរួមប្រជុំ នៅទីក្រុងហ្សឺណែវនៅថ្ងៃនេះ នាឱកាសបើកសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សនៃ ស្ថាប័នពិភពលោក ថា អង្គការសហប្រជាជាតិមានអណត្តិ និងឧបករណ៍ដែលខ្លួនត្រូវការចាំបាច់ក្នុងការបង្ការទប់ស្កាត់ការរំលោភសិទ្ធិមនុស្ស ទន្ទឹមនឹងនេះ លោកបានក្រើនរំលឹកផងដែរថា បញ្ហាប្រឈមធំបំផុតចំពោះការប្រើប្រាស់ឧបករណ៍ទាំងនេះ គឺ កង្វះការព្រមព្រៀងជាឯកច្ឆន្ទក្នុងចំណោមរដ្ឋជាសមាជិកនានា។

លោក បាន បានមានប្រសាសន៍តាមរយៈសារជាវីដេអូ នាឱកាសបើកវេទិកានយោបាយកម្រិតខ្ពស់ដែលមានរយៈពេលបីថ្ងៃនៃសម័យប្រជុំលើកទី ២៨ របស់ស្ថាប័នមួយដែលមានសមាជិកចំនួន ៤៧ រូប ថា "ខ្ញុំសូមអំពាវនាវដល់ក្រុមប្រឹក្សាសិទ្ធិមនុស្សឲ្យរួបរួមគ្នាត្រៀមខ្លួនជាស្រេច និងមានវិធានការជាក់ស្តែង ដើម្បីគាំទ្រតួអង្គថ្នាក់ជាតិ ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស។ មានវិធានការជាមុនលើបញ្ហាសិទ្ធិមនុស្ស ជួយពង្រឹងអធិបតេយ្យភាពជាតិ ប្រសើរជាជាងការប្រឈម ឬការប្រឆាំងនឹងការរំលោភនោះ។"

លោក អគ្គលេខាធិការ ដោយមានការចូលរួមពីប្រធានក្រុមប្រឹក្សា គឺ លោក ចៅជីម រ៉ាក់ឃើរ (Jaochim Rucker) និងឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស លោក ហ្សេអ៊ីដ រ៉ាអាដ អាល ហ៊ូសេន បានមានប្រសាសន៍បន្ថែមថា "ពិភពលោកប្រឈមនឹងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ចាប់ពីការរើសអើង និងវិសមភាពរហូតដល់ការបង្ក្រាប និងអំពើជ្រុលនិយមហិង្សា។ បញ្ហាប្រឈមរួមរបស់យើងគឺ ត្រូវខិតខំប្រឹងប្រែងធ្វើឲ្យបានច្រើនបន្ថែមទៀត ដើម្បីបន្តទប់ស្កាត់បញ្ហាទាំងនេះ និងការរំលោភបំពានផ្សេងទៀត មុនពេលដែលករណីទាំងនេះកើតឡើង។"

ក្រុមប្រឹក្សានេះបានស្តាប់ផងដែរ នូវសេចក្តីថ្លែងការណ៍ពីប្រធានាធិបតីសាធារណរដ្ឋម៉ាសេដ្វាន អតីតយូហ្គោស្លាវី នាយករដ្ឋមន្ត្រីនៃប្រទេសហ្វីជី ព្រមទាំងឥស្សរជនជាន់ខ្ពស់នានាមកពីរដ្ឋចំនួន ២០ ដែលបានលើកឡើងអំពីកង្វល់របស់ខ្លួនចំពោះស្ថានភាពក្នុងប្រទេសមួយចំនួននៅជុំវិញពិភពលោក និងបានគូសបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងមួយចំនួនដែលប្រទេសខ្លួន បាន និងកំពុងធ្វើ ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស។"

លោក បាន បានហៅកិច្ចការពារ និងការធ្វើឲ្យសម្រេចឲ្យបានសិទ្ធិមនុស្ស ថា "មានសារសំខាន់បំផុតសម្រាប់របៀបវារៈទាំងមូលរបស់អង្គការសហប្រជាជាតិ" និងបានសង្កត់ធ្ងន់ពីតួនាទីកសាងសមត្ថភាព ការឃ្លាំមើល និងការធ្វើរបាយការណ៍ រាប់ទាំងតាមរយៈ ការងារនៃគំនិតផ្តួចផ្តើមសិទ្ធិមនុស្សស្ថិតនៅជួរមុខគេ។ "ជម្លោះនៅប្រទេសស៊ីរី គឺជាឧទាហរណ៍មួយ ដែលកិច្ចខិតខំប្រឹងប្រែងត្រៀមបង្ការជាមុនរបស់អង្គការសហប្រជាជាតិដើម្បីដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្ស អាចបញ្ចៀសបាននូវមហន្តរាយដល់មនុស្ស និងនយោបាយ" លោក មានប្រសាសន៍ដោយសង្កត់ធ្ងន់ថា រដ្ឋជាសមាជិកទាំងអស់ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីបង្កើត "ការផ្លាស់ប្តូរដែលមិនអាចអត់បាន" នេះ នៅក្នុងវិធីអនុវត្តការងាររបស់ខ្លួន។

ឧត្តមស្នងការសិទ្ធិមនុស្ស លោក ហេ្សអ៊ីដ រ៉ាអាដ អាល ហ៊ូហេ្សន បានថ្លែងផងដែរ ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សជាលើកដំបូង ចាប់ពីពេលដែលលោកចូលកាន់តំណែងនៅឆ្នាំមុន ថា ពិភពលោកត្រូវតែមាន "គោលការណ៍ច្បាស់លាស់ ហើយការឆ្លៀសវៃគ្រប់គ្រាន់ ក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ខ្លួន ដើម្បីកាច់ចង្កូម" ពួកជ្រុលនិយមហិង្សា។

"សម្រាប់យើងទាំងអស់គ្នា ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ មិនអាចឲ្យជនណាម្នាក់ប្រើប្រាស់ធ្វើជាការលេងសើច ឬដើម្បីបំភាន់ភ្នែកឡើយ ផ្ទុយទៅវិញ ច្បាប់ទាំងនេះ ត្រូវតែបានអនុវត្តយ៉ាងពេញលេញ" លោក ហេ្សអ៊ីដ បានសង្កត់ធ្ងន់ដូច្នេះ ដោយលើកអំពីរបៀបដែលថា បើទោះជាធម្មនុញ្ញអង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើងតាំងពី ៧០ ឆ្នាំមុន ក្តី ក៏នៅតែកើតមានជាប្រក្រតីគួរឲ្យភ្ញាក់ផ្អើល នូវការមិនគោរព និងការរំលោភសិទ្ធិមនុស្ស ដែលមានពេលខ្លះ ករណីនេះអាចឈានដល់កម្រិតមួយ គួរឲ្យតក់ស្លុតក៏សឹងមាន។

លោក បានមានប្រសាសន៍ថា រដ្ឋមួយចំនួន លើកសំអាងពីករណីពិសេស ឬករណីអញ្ញត្រកម្ម។ "រដ្ឋទាំងនោះ ចាប់ច្បិច និងជ្រើសរើសយកការអនុវត្តរវាងសិទ្ធិផ្សេងៗ។ រដ្ឋាភិបាលមួយ អាចនឹងគាំទ្រទាំងស្រុងចំពោះសិទ្ធិមនុស្សរបស់ស្ត្រី និងសិទ្ធិរបស់សហគមន៍មនុស្សស្រីស្រឡាញ់មនុស្សស្រី មនុស្សប្រុសស្រឡាញ់មនុស្សប្រុស មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ (LGBT) ប៉ុន្តែមានការអល់អែកចិត្តនឹងការលើកឡើងណាមួយថា សិទ្ធិទាំងនោះត្រូវអនុវត្តផងដែរ ចំពោះទេសន្តរប្រវេសន៍ដែលមានស្ថានភាពមិនប្រក្រតី។ រដ្ឋមួយទៀត អាចនឹងគោរពយ៉ាងហ្មត់ចត់ចំពោះសិទ្ធិអប់រំ ប៉ុន្តែអាចនឹងជំទាស់ទាំងស្រុង ចំពោះទស្សនៈនយោបាយណាដែលប្រឆាំង។ រដ្ឋទីបីមួយ អាចនឹងរំលោភទូទៅលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃប្រជាពលរដ្ឋរបស់ខ្លួន ទន្ទឹមនឹងនេះ រដ្ឋនេះការពារយ៉ាងខ្លាំងក្លានូវឧត្តមគតិសិទ្ធិមនុស្ស នៅចំពោះមុខប្រទេសជាមិត្តរបស់ខ្លួន។"

"ភស្តុតាងមួយចំនួន អាចមានការលាក់កំបាំង។ ប៉ុន្តែនៅក្នុងប្រទេសជាច្រើន ការពិតអំពីការសម្លាប់រង្គាល និងអំពើហិង្សាផ្លូវភេទ ភាពក្រីក្រដែលរងការរិះគន់យ៉ាងខ្លាំង ការប្រគល់ផ្តាច់មុខនូវសេវាគាំពារសុខភាព និងធនធានសំខាន់ៗផ្សេងទៀតទៅឲ្យអ្នកមានទ្រព្យសម្បត្តិ និងមានខ្នងក្រាស់ ការធ្វើទារុណកម្មលើជនជាប់ឃុំដែលគ្មានអំណាច ការបដិសេធសេចក្តីថ្លៃថ្នូររបស់មនុស្ស - រឿងទាំងនេះ អ្នករាល់គ្នាក៏ដឹងដែរថាវាយ៉ាងណានោះ" លោក បានមានប្រសាសន៍ដូច្នេះ ដោយបញ្ជាក់បន្ថែមទៀតថា៖ "អញ្ចឹងទេ ប្រតិភូទាំងឡាយ កត្តាដែលធ្វើឲ្យរដ្ឋមួយមានកេរ្តិ៍ឈ្មោះពិតប្រាកដនោះ គឺវាគួបផ្សំផងដែរទៅនឹងវិធានការជាក់ស្តែង កាលបើវិធានការណាមួយនោះធ្វើឡើងសំដៅបង្ការទប់ស្កាត់ការរំលោភបំពាន និងការដោះស្រាយបញ្ហាវិសមភាពសង្គម ទៅវិញទេ។"

ឧត្តមស្នងការ បានមានប្រសាសន៍ថា លោក "មានកង្វល់ជាខ្លាំង" ដោយការមិនគោរពពីសំណាក់រដ្ឋមួយចំនួន ចំពោះអ្នកជំនាញការឯករាជ្យរបស់ក្រុមប្រឹក្សា - និងដោយការសងសឹក និងយុទ្ធនាការលាបពណ៌គ្នាផងដែរ ដែលជាញឹកញយបំផុត ត្រូវបានធ្វើឡើងប្រឆាំងនឹងតំណាងសង្គមស៊ីវិល។

ការវាស់វែងពិតប្រាកដតែមួយគត់អំពីតម្លៃរបស់រដ្ឋាភិបាលមួយ មិនមែនទៅលើការបង្ហាញមុខមាត់របស់ខ្លួនជាឱឡារិកអំពីការទូតដ៏មហិមាឡើយ។ ប៉ុន្តែ វាគឺជាវិសាលភាពទៅវិញទេ ដែលរដ្ឋនោះឆ្លើយតបបានឆាប់រហ័សកម្រិតប៉ុនណាចំពោះសេចក្តីត្រូវការ និងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋខ្លួន និងមនុស្សដទៃផ្សេងទៀត

ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន លោក ហ្សេអ៊ីដ បានមានប្រសាសន៍ដូច្នេះ ដោយបានអំពាវនាវឱ្យរដ្ឋជាសមាជិកធ្វើការសម្របសកម្មភាពរបស់ខ្លួន ជាមួយនឹងអនុសាសន៍របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។

ក្នុងនាមជាស្ថាប័នអន្តររដ្ឋាភិបាលមួយនៅក្នុងប្រព័ន្ធ អ.ស.ប ក្រុមប្រឹក្សាសិទ្ធិមនុស្ស ទទួលខុសត្រូវក្នុងការពង្រឹងការការពារសិទ្ធិមនុស្សនៅទូទាំងពិភពលោក និងទទួលខុសត្រូវដោះស្រាយស្ថានភាពរំលោភសិទ្ធិមនុស្ស និងផ្តល់អនុសាសន៍លើបញ្ហាទាំងនោះ។

លោក ហ្សេអ៊ីដ បានកោតសរសើរការងាររបស់បុគ្គលិកទាំងអស់របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ជាពិសេស បុគ្គលិកទាំងឡាយដែលធ្វើការក្នុងស្ថានភាពគ្រោះថ្នាក់ជារៀងរាល់ថ្ងៃ។ លោក បានសម្តែងនូវការស្រងាកចិត្តពេលដែលបានដឹងថា៖ "ដោយសារតែរដ្ឋជាសមាជិកនានាខ្វះឆន្ទៈ" ទើបបានជា អ.ស.ប មិនមានតួនាទី ដើម្បីធ្វើការផ្តល់ការគាំទ្រឲ្យបានគ្រប់គ្រាន់ដល់បុគ្គលិក ដែលត្រូវបានរងរបួសនៅក្នុងបេសកកម្មដែលមានហានិភ័យខ្ពស់ ឬដល់ក្រុមគ្រួសាររបស់បុគ្គលិក ដែលត្រូវបានគេសម្លាប់នៅក្នុងករណីដូច្នេះ។

លោក បានមានប្រសាសន៍ថា៖ "និយាយតាមត្រង់ទៅ នេះជាការរន្ធត់ចិត្ត ហើយខ្ញុំអំពាវនាវដល់អ្នកទាំងអស់គ្នា ឲ្យផ្លាស់ប្តូរស្ថានភាពនេះ។"

ថ្លែងផងដែរទៅកាន់ក្រុមប្រឹក្សា តាមរយៈសារវីដេអូ ប្រធានមហាសន្និបាត លោក សេម គូតេសា (Sam Kutesa) បានមានប្រសាសន៍ថា រដ្ឋជាសមាជិកទាំងអស់ ត្រូវមានទំនួលខុសត្រូវធំជាងគេបង្អស់ ក្នុងការការពារពលរដ្ឋរបស់ខ្លួន និងផ្តល់ឲ្យពួកគេនូវសិទ្ធិមនុស្សដែលបានទទួលស្គាល់ជាអន្តរជាតិ ។ ដោយសារតែហេតុនេះហើយ ទើបក្រុមប្រឹក្សាសិទ្ធិមនុស្សចាំបាច់ត្រូវពិនិត្យពិចារណាលើចំណុចនេះ នៅពេលដោះស្រាយបញ្ហាប្រឈមអំពីសិទ្ធិផ្សេងៗ ហើយប្រើប្រាស់យន្តការត្រួតពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ នោះ។

លោក បានមានប្រសាសន៍ថា "នាពេលថ្មីៗនេះ នៅជុំវិញពិភពលោក យើងបានឃើញការកើនឡើងគួរឲ្យព្រួយបារម្ភមួយ ក្នុងរូបភាពជាច្រើននៃការមិនចេះអត់ឱន ការរើសអើង និងភាពអគតិ។ ឥរិយាបថទាំងនេះ បានបន្សល់ទុកនូវលទ្ធផលអវិជ្ជមានជាច្រើន ជាអាទិ៍ គំនិតចាស់កំរឹល ស្លាកស្នាមទុយ៌ស/ស្ទិកម៉ា ការផាត់ចេញការគំរាមកំហែង និងរហូតដល់អំពើហិង្សាធ្ងន់ធ្ងរក៏សឹងមាន។"

លោក គូតេសា បានអំពាវនាវឲ្យក្រុមប្រឹក្សាសិទ្ធិមនុស្ស ផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច ហើយជាពិសេស គឺសិទ្ធិអភិវឌ្ឍ ដោយសារថា សិទ្ធិទាំងនេះគឺជាស្នូល សម្រាប់ការឈានទៅសម្រេចបានកម្រិតជីវភាពរស់នៅមួយដែលអាចទទួលយកបាន នៅក្នុងវិស័យដែលប្រឈមបំផុតខាងសេដ្ឋកិច្ចនៃពិភពលោក។

លោក បានបន្ថែមថា៖ "ខណៈដែលយើងបង្កើតក្របខ័ណ្ឌអភិវឌ្ឍថ្មី ឈានទៅរកការផ្លាស់ប្តូរមួយ ក្នុងឆ្នាំនេះ នៅអង្គការសហប្រជាជាតិ យើងត្រូវចាំទុកក្នុងចិត្តផងដែរ អំពីទំនាក់ទំនងមិនអាចកាត់ផ្តាច់បាន រវាងការអភិវឌ្ឍ និងសិទ្ធិមនុស្ស។"